# 10 ព្រៃឈើ

**នៅក្នុងជំពូកនេះ :** **ទំព័រ**


សាច់រឿង : ចលនាខ្សែក្រវ៉ាត់បៃតង ....176
ព្រៃឈើ និងសុខភាព ....177
បន្ទុករបស់ស្ត្រី .... 180
ព្រៃឈើ និងការចិញ្ចឹមជីវិត ....181
សាច់រឿង : ការការពារព្រៃឈើ និងការចិញ្ចឹមជីវិត ....182
អេកូទេសចរណ៍ ....183
ផលិតផលមិនមែនឈើ ....183
សាច់រឿង : ការប្រមូលឱសថពីព្រៃឈើ....184
ការកាប់បំផ្លាញព្រៃឈើ ....185
ជម្លោះព្រៃឈើ ....186
សកម្មភាព : ល្បែងសង្គម ....186
ការប្រើប្រាស់ព្រៃឈើប្រកបដោយស្ថិរភាព ....189
សកម្មភាព : ប្រើប្រាស់ចំណេះដឹងរបស់មនុស្សគ្រប់គ្នា ពិចារណាពីតម្រូវការ
របស់មនុស្សគ្រប់គ្នា....191
រៀបចំផែនការគ្រប់គ្រងព្រៃឈើ ....192
ភាពជាដៃគូការពារព្រៃឈើ ....193
សាច់រឿង : ការធ្វើការរួមគ្នាដើម្បីការពារព្រៃទឹកភ្លៀងអាម៉ាហ្សូន ....193
ការអភិរក្សព្រៃឈើ ....194
សាច់រឿង : រុក្ខសាស្ត្រដែលថែរក្សាទាំងមនុស្សនិងដើមឈើ ....195
ការដាំដើមឈើឡើងវិញ....196
តើការដាំដើមឈើតែងតែមានប្រយោជន៍ឬ? ....196

# ព្រៃឈើ



ព្រៃឈើផ្តល់ឲ្យយើងនូវធនធានដ៏សំខាន់ៗ ដូចជាអាហារ, ឧស, សម្ភារៈសំណង់, ស្មៅចំណីសត្វ, ឱសថ, និងច្រើនទៀត។ ដើមឈើ និងព្រៃឈើក៏មានតួនាទីសំខាន់ផងដែរក្នុងការរក្សាស្ថិរភាពនៃបរិស្ថានល្អ។ វាធ្វើឲ្យខ្យល់និងទឹកមានសភាពស្អាត, បង្ការសំណឹកដី និងទឹកជំនន់, បង្កើនជីជាតិដី, ផ្តល់ជម្រកសម្រាប់សត្វបក្សា សត្វបក្សី និងរុក្ខជាតិ, ផ្តល់ម្លប់, និងធ្វើឲ្យសហគមន៍យើងស្រស់បំព្រង។

ដើម្បីឲ្យព្រៃឈើបន្តផ្តល់នូវធនធាន និងរក្សាស្ថិរភាពបរិស្ថានល្អ មនុស្សត្រូវតែថែទាំព្រៃឈើឲ្យបានល្អ, ចាត់ចែងយ៉ាងយុត្តិធម៌, និងប្រើប្រាស់ដោយប្រយ័ត្នប្រយែង។ ប៉ុន្តែដោយហេតុថាឧស្សាហកម្មក៏មើលឃើញពីផលប្រយោជន៍នៃធនធានព្រៃឈើដូចសហគមន៍ដែរ និងដោយហេតុថាជួនកាលមនុស្សចង់យកដីក្នុងព្រៃមកប្រើប្រាស់ក្នុងបំណងផ្សេងៗ ទើបព្រៃឈើនៅទូទាំងពិភពលោកកំពុងត្រូវបានកាប់រំលំលឿនជាងពេលវេលាដែលវាអាចដុះមកវិញ។ ជួនកាលក្រុមហ៊ុនឈើ ឬឧស្សាហកម្មដទៃទៀតដែលរកស៊ីកាប់ព្រៃឈើ ដូចជាការជីករ៉ែជាដើម បានផ្តល់ប្រភពចំណូលដល់ប្រជាជនដែលកំពុងត្រូវការវាយ៉ាងខ្លាំង។

ទោះជាយ៉ាងនេះក្តី គេអាចស្វែងរកតុល្យភាពរវាងតម្រូវការប្រើប្រាស់ដីនិងធនធាន និងតម្រូវការនៃការការពារធនធានទាំងនេះសម្រាប់អនាគតបាន។ នៅពេលមានការប្រើប្រាស់ធនធានច្រើនពេក វាបង្កគ្រោះថ្នាក់យ៉ាងធំ និងយូរអង្វែង។ សហគមន៍ជាច្រើនដែលបានរស់នៅអាស្រ័យព្រៃឈើជាច្រើនជំនាន់មកហើយ ដឹងថាពួកគេនឹងរងគ្រោះយ៉ាងធ្ងន់ធ្ងរប្រសិនបើព្រៃឈើត្រូវបានប្រើប្រាស់ ឬកាប់ឆ្ការច្រើនពេក។

## ចលនាខ្សែក្រវាត់បៃតង

អ្នកស្រី វ៉ានការីម៉ាថៃ រស់នៅក្នុងប្រទេសកេនយ៉ា ក្នុងភាគខាងកើតនៃទ្វីបអាហ្វ្រិក និយាយថា កាលពីមុនភ្នំកេនយ៉ាធ្លាប់តែមានភាពអៀនខ្មាស់ គឺតែងតែលាក់ខ្លួនពីក្រោយពពកជានិច្ច។ ភ្នំនេះស័ក្តិសិទ្ធិណាស់សម្រាប់ប្រជាជន ព្រោះមានទន្លេជាច្រើនហូរមកពីព្រៃឈើក្រាស់ឃ្មឹកដែលគ្របដណ្តប់ជម្រាលភ្នំ។ សព្វថ្ងៃភ្នំកេនយ៉ាលែងមានភាពអៀនខ្មាស់ទៀតហើយ។ ពពកដែលធ្លាប់តែបាំងបិទភ្នំលែងមានទៀតហើយ ហើយព្រៃឈើក៏ដូចគ្នាដែរ។ ជាមួយនឹងការបាត់បង់ព្រៃឈើនិងពពកដូចនេះ ទន្លេទាំងឡាយក៏ចាប់ផ្តើមរីងស្ងួតដែរ។

នៅពេលអ្នកស្រីវ៉ានការី ធំដឹងក្តី គាត់បានឃើញពីរបៀបដែលការកាប់បំផ្លាញព្រៃឈើនាំឲ្យមានសំណឹកដី, បាត់បង់ប្រភពទឹក, និងពិបាករកឧសដុត។ គាត់ក៏ចាប់ផ្តើមយល់ថា ការកាប់បំផ្លាញព្រៃឈើបណ្តាលឲ្យមានភាពក្រីក្រ និងភាពរាំងស្ងួត។ ដូច្នេះហើយទើបអ្នកស្រីវ៉ានការី ចាប់ផ្តើមដាំដើមឈើឡើងវិញ។

អ្នកស្រីបានរៀបចំស្រ្តីមួយក្រុមនាំគ្នាដាំដើមឈើនៅជុំវិញផ្ទះ និងចម្ការរបស់ខ្លួន។ ដោយសារពួកគេដាំដើមឈើជាជួរៗ ឬដូច "ខ្សែក្រវាត់" នោះទើបគេស្គាល់ក្រុមគាត់ថា ជាចលនាខ្សែក្រវាត់បៃតង។ ស្ត្រីក្នុងចលនាខ្សែក្រវាត់បៃតង ចាប់ផ្តើមបង្រៀនប្រជាជនដទៃទៀតឲ្យយល់អំពីផលប៉ះពាល់ពីការកាប់បំផ្លាញព្រៃឈើ និងបង្រៀនឲ្យដាំដើមឈើជាមួយពួកគេ។ ពួកគេបានយកដើមឈើឲ្យកសិករ រួចដាំវានៅលើជាយភ្នំដើម្បីបង្ការសំណឹកដី។ តាមរយៈការដាំដើមឈើទាំងនៅទីក្រុងនិងតាមភូមិដើម្បីបង្កើតកន្លែងបៃតង ផ្តល់ម្លប់ និងផ្តល់ឧសដុត, ពួកគេបានបង្ហាញថា ការដាំដើមឈើអាចដោះស្រាយបញ្ហាជាច្រើន។ ចលនាខ្សែក្រវាត់បៃតងក៏បានធ្វើសួនដំណាំ, សាងសង់ទំនប់តូចៗដើម្បីប្រមូលទឹកភ្លៀង, និងបើកសិក្ខាសាលាដើម្បីជួយប្រជាជនឲ្យយល់ដឹងអំពីតម្រូវការនៃព្រៃឈើល្អ។

ដោយការទទួលខុសត្រូវលើបរិស្ថានរបស់ខ្លួន ចលនាខ្សែក្រវាត់បៃតងបានស្វែងយល់ថាពួកគេត្រូវការគាំទ្រពីរដ្ឋាភិបាលរបស់ខ្លួនក្នុងការថែទាំបរិស្ថានដើម្បីជាផលប្រយោជន៍សម្រាប់ប្រជាជនកេនយ៉ាគ្រប់រូប។ ការដាំដើមឈើបានក្លាយជាពាក្យស្លោកមួយនៃចលនាដើម្បីសន្តិភាព និងប្រជាធិបតេយ្យនៅក្នុងប្រទេសកេនយ៉ា។ នៅពេលមានជម្លោះកើតឡើងរវាងសហគមន៍ខុសគ្នា ចលនាខ្សែក្រវាត់បៃតងបានប្រើពាក្យស្លោក "ដើមឈើសន្តិភាព" ដើម្បីជួយសម្រុះសម្រួលពួកគេឲ្យស្រឡាញ់រាប់អានគ្នាវិញ។

ពីស្ត្រីម្នាក់ដែលដាំដើមឈើ វ៉ានការីបានក្លាយជាវីរនារីម្នាក់ក្នុងប្រទេសគាត់។ ប៉ុន្តែគាត់ក៏បានប្រឈមនឹងការលំបាកជាច្រើន។ ប្តីរបស់គាត់បានចាកចោលគាត់ ព្រោះតែមិនអាចរស់នៅជាមួយស្ត្រីម្នាក់ដែលពូកែដូច្នេះ។ រដ្ឋាភិបាលបានចាប់ខ្លួនគាត់ ព្រោះតែគាត់បានរៀបចំចលនាជាមួយប្រជាជនក្រីក្រ។ ប៉ុន្តែដោយសារភាពក្លាហានរបស់គាត់ និងការរួមគ្នាពីសំណាក់ប្រជាជនកេនយ៉ារាប់ពាន់នាក់ ចលនាខ្សែក្រវាត់បៃតងបានទទួលជោគជ័យក្នុងការដាំដើមឈើរាប់លានដើម។

នៅឆ្នាំ២០០៤ អ្នកស្រីវ៉ានការីម៉ាថៃ ទទួលបានពានរង្វាន់សន្តិភាព ដែលជារង្វាន់កិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតមួយនៅក្នុងពិភពលោក។ រង្វាន់នេះបានផ្តល់ឲ្យគាត់ដោយសារការលើកកម្ពស់សន្តិភាពតាមរយៈការអភិវឌ្ឍដែលមានស្ថិរភាព ដែលរួមបញ្ចូលប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងសមភាពស្ត្រី។ ហើយទាំងអស់នេះចាប់ផ្តើមឡើងដោយការដាំដើមឈើ។



# ព្រៃឈើ និងសុខភាព

ព្រៃឈើជួយគាំទ្រសុខភាពមនុស្សនៅគ្រប់ទីកន្លែង។ សូម្បីតែមនុស្សដែលរស់នៅឆ្ងាយពីព្រៃឈើ ឬក្នុងតំបន់ដែលមានការបំផ្លាញព្រៃឈើយ៉ាងធ្ងន់ធ្ងរក៏ដោយ ក៏ពួកគេពឹងផ្អែកលើវត្ថុផ្សេងៗដែលព្រៃឈើផ្តល់ឲ្យដែរ។ នៅពេលព្រៃឈើត្រូវបានកាត់បន្ថយឬបំផ្លាញ សុខភាពសហគមន៍ក៏ទទួលការគំរាមកំហែង ព្រោះដំណើរការនិងមុខងារទាំងឡាយរបស់ដើមឈើក្នុងការជួយគាំទ្រសុខភាពមនុស្ស មិនត្រូវបានធ្វើចប់សព្វគ្រប់ទេ។




**ដើមឈើនិងព្រៃឈើ ទ្រទ្រង់សុខភាពនិងសុខុមាលភាពរបស់សហគមន៍តាមរបៀបច្រើនយ៉ាង។**



## ព្រៃឈើ និងទឹក

មនុស្សមួយចំនួនជឿថា ដើមឈើទាក់ទាញទឹកភ្លៀង និងទប់ទឹកនៅក្បែរដី។ អ្នកខ្លះទៀតជឿថាដើមឈើប្រើប្រាស់ទឹកច្រើនជាងការបញ្ចេញមកវិញ ដូច្នេះវារារាំងដល់ការដាំដំណាំ។ ជំនឿទាំងពីរនេះអាចត្រឹមត្រូវដូចគ្នា អាស្រ័យលើប្រភេទដើមឈើ, កន្លែងដែលដាំវា, និងលក្ខខណ្ឌដទៃទៀត។

ដីដែលសម្បូរព្រៃឈើ និងឫសឈើជ្រៅៗ ដើរតួរជាអ្នកច្រោះទឹក។ នៅពេលដែលថ្នាំសម្លាប់សត្វល្អិត, លោហៈធ្ងន់, និងសារធាតុគីមីពុលដទៃទៀត, ធ្វើឲ្យទឹកលើដី និងក្រោមដីក្លាយជាកខ្វក់ ព្រៃឈើជួយច្រោះសារធាតុទាំងនេះចេញពីទឹក។ ទឹកដែលបានច្រោះរួច ហូរចូលក្នុងអណ្តូងរបស់យើង, ខ្សែទឹក, បឹង, ហើយធ្វើឲ្យទីជម្រាល និងប្រជាជនដែលរស់ក្នុងទីជម្រាល មានសុខភាពល្អ។ បើគ្មានព្រៃឈើសម្រាប់ការពារប្រភពទឹកទេ នោះនឹងមានទឹកតិចតួចសម្រាប់ផឹកនិងងូត។ ដោយមូលហេតុទាំងអស់នេះ ជាការប្រសើរបំផុតគឺត្រូវទុកដើមឈើឲ្យដុះចោល ជាជាងការកាប់រំលំវា ជាពិសេសបើទឹករបស់អ្នកមានច្រើននិងស្អាត។

ប៉ុន្តែដើមឈើប្រភេទខ្លះ ជាពិសេសដើមឈើដែលលូតលាស់ឆាប់រហ័ស និងមិនមែនជាដើមឈើក្នុងតំបន់វាទេ(មើលទំព័រ202) នោះវាអាចស្រូបយកទឹកច្រើន។ សម្រាប់កសិករ និងអ្នកដទៃទៀតដែលចង់ការពារប្រភពទឹក ជាការសំខាន់គួរសង្កេតមើលប្រភេទផ្សេងៗគ្នានៃដើមឈើដែលស្រូបទឹក និងគួរសម្រេចចិត្តដោយប្រុងប្រយ័ត្នថាដើមឈើប្រភេទណាដែលគួរដាំ។

## ព្រៃឈើ និងអាកាសធាតុ

ព្រៃឈើមានឥទ្ធិពលយ៉ាងសំខាន់លើអាកាសធាតុ និងបរិយាកាស(អាកាសធាតុនៅទីកន្លែងមួយក្នុងរយៈពេលយូរអង្វែង)។ ព្រៃឈើជួយសម្រួលអាកាសធាតុ ដោយធ្វើឲ្យខ្យល់ក្តៅចុះត្រជាក់ និងមានសំណើមខ្លះ, និងធ្វើឲ្យខ្យល់ត្រជាក់មានកម្តៅ និងស្ងួតខ្លះ។ ដើមឈើការពារផ្ទះសម្បែង និងដំណាំពីខ្យល់ខ្លាំងនិងថ្ងៃក្តៅ និងផ្តល់ជម្រកការពារពីភ្លៀងធំៗ។



ក្នុងទ្រង់ទ្រាយធំ ព្រៃឈើប្រឆាំងនឹងការឡើងកម្តៅផែនដី(មើលទំព័រ33) តាមរយៈការស្រូបយកសារធាតុពុល។ ធ្វើដូចនេះជួយរក្សាបរិយាកាសនៃផែនដីទាំងមូលឲ្យមានសភាពសមរម្យ។ នៅពេលយើងបាត់បង់ព្រៃឈើក្នុងទ្រង់ទ្រាយធំ ការគំរាមកំហែងនៃគ្រោះមហន្តរាយធម្មជាតិនឹងកើនឡើង ដូចជាព្យុះហ៊ីរីយ៉ែន, ភាពរាំងស្ងួត, និងរលកក្តៅ។



**ទីណាដែលមានការកាប់បំផ្លាញព្រៃឈើ អាកាសធាតុនឹងកាន់តែអាក្រក់ជាខ្លាំង។**

## ព្រៃឈើបង្ការសំណឹកដី និងកាត់បន្ថយជំនន់

ដើមឈើបង្ការសំណឹកដី និងកាត់បន្ថយជំនន់ តាមរយៈការបន្ថែមស្លឹកឈើទៅលើដី, ផ្តល់ម្លប់ដល់រុក្ខជាតិដែលដុះក្រោមដើមឈើ, និងទប់ដីដោយឫសរបស់វា។ ព្រៃឈើបន្ថយល្បឿនទឹកភ្លៀងហូរ និងបំបែកខ្សែទឹកពាសពេញដី ដូច្នេះវានឹងជ្រាបទៅក្នុងដីជាជាងហូរហៀរលើដី។

នៅពេលព្រៃឈើត្រូវបានកាប់បំផ្លាញ ដីត្រូវបានហូរជាច់ទៅក្នុងទន្លេ និងខ្សែទឹក។ នៅពេលមានព្យុះមកដល់ ដីមិនអាចស្រូបយក និងរក្សាទុកទឹកភ្លៀងទៀតទេ។ ផ្ទុយទៅវិញ ទឹកភ្លៀងនឹងហូរកាន់តែលឿនឆ្លងកាត់ផ្ទៃដី រួចបង្កជាជំនន់។ ការថែរក្សាដើមឈើនិងព្រៃឈើ គឺជាការសំខាន់ក្នុងការការពារលំហូរធម្មជាតិនៃទឹកឆ្លងកាត់ទីជម្រាល។ (សម្រាប់ព័ត៌មានអំពីសកម្មភាពដែលបង្ហាញថា តើទឹកភ្លៀងធ្វើអ្វីខ្លះមកលើដីវាល, សូមមើលទំព័រ289)។



# ព្រៃឈើចម្រុះ និងសុខភាព

នៅក្នុងព្រៃ យើងអាចមើលឃើញពីសំណាញ់នៃជីវិត(មើលទំព័រ27)បានយ៉ាងងាយ ព្រោះព្រៃឈើមានរុក្ខជាតិ និងសត្វជាច្រើនប្រភេទខុសប្លែកពីគ្នា។ ភាពចម្រុះនៃជីវិតបែបនេះ ការពារសុខភាពមនុស្ស តាមវិធីច្រើនយ៉ាង។ សត្វឃ្មុំនិងសត្វល្អិតដទៃទៀត ដែលរស់នៅលើដើមឈើ រោយលម្អងលើដំណាំ ដូច្នេះដំណាំនឹងចេញផ្កានិងផ្លែ។ សត្វឪម៉ាល់ និងស្រមោច ស៊ីសត្វល្អិតទាំងឡាយដែលស៊ីដំណាំ។ សត្វប្រចៀវនិងសត្វស្លាប ស៊ីសត្វមូសដែលចម្លងជំងឺគ្រុនចាញ់, ជំងឺគ្រុនលឿង, និងជំងឺដទៃទៀត។ សត្វព្រៃដទៃទៀត គ្រប់គ្រងកណ្តុរ, ចៃ, សត្វ, និងរុយ ដោយការចាប់ស៊ី និងដេញវាចេញឲ្យឆ្ងាយ និងបង្ការវាមិនឲ្យចម្លងជំងឺ។

នៅពេលសាងសង់ផ្ទះសម្បែងនៅក្នុងឬនៅក្បែរព្រៃឈើដែលមានការកាប់បំផ្លាញ ចំនួននិងភាពចម្រុះនៃសត្វ មានការថយចុះ ព្រោះប្រភពជម្រកនិងអាហាររបស់ពួកវា លែងសូវសម្បូរនិងលែងសូវមានភាពចម្រុះ។ ម្យ៉ាងទៀតសត្វដែលនៅសល់ក្នុងព្រៃ ត្រូវបានបង្ខំឲ្យរស់នៅក្បែរប្រជាជន។ ធ្វើដូចនេះនាំឲ្យមានឱកាសខ្ពស់នៃការចម្លងជំងឺសត្វទៅកាន់មនុស្ស។ តាមរយៈការថែរក្សាព្រៃឲ្យបានគ្រប់គ្រាន់ដើម្បីជួយទ្រទ្រង់ភាពចម្រុះនៃរុក្ខជាតិនិងសត្វ គឺយើងការពារសុខភាពមនុស្សដែរ។

# ព្រៃឈើ អាហារ ឧសដុត និងឱសថ




ព្រៃឈើមានផ្លែឈើ, គ្រាប់ផ្លែឈើ, គ្រាប់ពូជ, ឫសឈើ, សត្វល្អិត, និងសត្វព្រៃដ៏ច្រើនសម្បូរបែប សម្រាប់ជាតម្រូវការរបស់មនុស្ស។

នៅពេលព្រៃឈើនៅសល់តិច វាច្រើនតែបណ្តាលឲ្យមានភាពអត់ឃ្លាន, កង្វះអាហារូបត្ថម្ភ, និងជំងឺ។ ប្រជាជនដែលពឹងផ្អែកលើធនធានទាំងនេះ ត្រូវរកវិធីផ្សេងៗដើម្បីរស់។ នៅពេលអាហារនិងឱសថពីព្រៃឈើបានបាត់បង់ ចំណេះវិជ្ជាក្នុងការរៀបចំ និងប្រើប្រាស់វា ក៏បាត់បង់ដែរ។ បែបនេះមានន័យថា ការបាត់បង់ព្រៃឈើ នាំឲ្យបាត់បង់ចំណេះវិជ្ជា និងទំនៀមទម្លាប់សំខាន់ៗផងដែរ។

នៅកន្លែងដែលខ្វះខាតធនធាន មនុស្សជួនកាលមានអារម្មណ៍ថាត្រូវបានបង្ខំឲ្យជ្រើសរើសរវាងការទុកដើមឈើ និងការកាប់ដើមឈើដើម្បីដាំដំណាំ។ ប៉ុន្តែការទុកដើមឈើខ្លះៗគឺជាការសំខាន់ ទោះបីកសិករត្រូវកាប់ឆ្ការព្រៃយកដីដាំដំណាំក៏ដោយ។ ក្នុងតំបន់ដែលកសិករត្រូវការដីក្នុងព្រៃ ជាការសំខាន់គឺត្រូវរក្សាតុល្យភាពរវាងព្រៃឈើ និងកសិកម្ម។ (សម្រាប់ព័ត៌មានបន្ថែមអំពីព្រៃឈើ និងកសិកម្ម សូមមើល ទំព័រ302)។

## បន្ទុករបស់ស្ត្រី

ភាគច្រើនគឺស្ត្រីនិងកុមារដែលជាអ្នកធ្វើការងារដ៏លំបាកក្នុងការស្វែងរក និងលីសែងឧសយកមកដុត។ បន្ទុកការងារនេះក្នុងរយៈពេលច្រើនឆ្នាំនឹងបណ្តាលឲ្យមានបញ្ហាសុខភាព។ នៅពេលមានការបំផ្លាញព្រៃឈើ មនុស្សត្រូវធ្វើដំណើរទៅទីឆ្ងាយៗដើម្បីស្វែងរកឧស។ បែបនេះធ្វើឲ្យពួកគេមានពេលវេលាតិចតួចសម្រាប់ធ្វើការងារសំខាន់ៗដទៃទៀតនៅឯផ្ទះ និងទៅសាលារៀន។

ស្ត្រីនិងកុមារក៏អាចប្រឈមនឹងអំពើហឹង្សាផ្លូវកាយនិងផ្លូវភេទផងដែរ នៅពេលពួកគេធ្វើដំណើរទៅស្វែងរកឧស។ ដោយមូលហេតុនេះហើយ ទើបនៅតំបន់ខ្លះស្ត្រីនិងក្មេងស្រីធ្វើដំណើរជាក្រុមទៅស្វែងរកឧសក្នុងពេលថ្ងៃ។ តាមរយៈការដាំនិងថែរក្សាដើមឈើឧសល្អៗនៅក្បែរផ្ទះ អ្នកទទួលបន្ទុករកឧស អាចមានសុវត្ថិភាពនិងសុខភាពល្អ។



**ការលីសែងវត្ថុធ្ងន់ៗទៅមកទីឆ្ងាយៗ ធ្វើឲ្យមានឈឺក្បាល ឈឺខ្នង និងជាពិសេសចំពោះកុមារ គឺខូចខាតឆ្អឹងកងខ្នង។**

# ព្រៃឈើ និងការចិញ្ចឹមជីវិត

ព្រៃឈើគឺជាប្រភពដ៏សំខាន់មួយសម្រាប់ការចិញ្ចឹមជីវិត។ រដ្ឋាភិបាលនិងអង្គការអន្តរជាតិមួយចំនួននិយាយថា ការកាប់បំផ្លាញព្រៃឈើដ៏ធ្ងន់ធ្ងរបំផុត គឺបង្កឡើងដោយប្រជាជនក្រីក្រដែលកាប់ព្រៃឈើយកដីធ្វើកសិកម្ម ឬចិញ្ចឹមជីវិតតាមវិធីផ្សេងៗទៀត។ ប៉ុន្តែនៅពេលប្រជាជនមិនមានអាហារ ប្រាក់ចំណូល និងតម្រូវការចាំបាច់ដទៃទៀតគ្រប់គ្រាន់ទេ តម្រូវការដើម្បីការរស់រានបានក្លាយជាបញ្ហាសំខាន់ជាងតម្រូវការនៃការថែរក្សាព្រៃឈើទៅទៀត។ ជួនកាលប្រជាជនគ្មានជម្រើសអ្វីក្រៅពីកាប់ដើមឈើឡើយ, អាចជាការកាប់ឆ្ការយកដីធ្វើកសិកម្ម ឬដើម្បីប្រមូលយកឧសនិងឈើ។ យើងកម្រឃើញមានការបន្ទោសលើការកាប់បំផ្លាញព្រៃឈើពីសំណាក់ឧស្សាហកម្មធំៗដែលយកឈើយ៉ាងច្រើន ឬកាប់ព្រៃឈើដើម្បីការជីករ៉ែ រុករកប្រេង ឬចម្ការកូនឈើទ្រង់ទ្រាយធំ។

នៅពេលប្រជាជនអាចបំពេញតម្រូវការប្រចាំថ្ងៃរបស់ខ្លួនបាន ពួកគេអាចគិតអំពីអនាគតបានកាន់តែល្អប្រសើរ រួមទាំងការថែទាំបរិស្ថានផងដែរ។ ប្រជាជនដែលរស់នៅក្នុងតំបន់ព្រៃឈើនិងដែលយកចិត្តទុកដាក់នឹងព្រៃឈើ ដឹងថាមានវិធីច្រើនយ៉ាងក្នុងការចិញ្ចឹមជីវិតដោយសារព្រៃឈើដោយមិនបណ្តាលឲ្យមានការបំផ្លាញច្រើនពេកទេ។ ក្នុងករណីជាច្រើន ការបំផ្លាញព្រៃឈើគឺបណ្តាលមកពីតម្រូវការរបស់ឧស្សាហកម្ម និងសម្ពាធនៃភាពក្រីក្រ។



ការកាប់បំផ្លាញព្រៃឈើបណ្តាលឲ្យមានភាពក្រីក្រ ហើយភាពក្រីក្របណ្តាលឲ្យមានការកាប់បំផ្លាញព្រៃឈើ។

# ការធ្វើកសិកម្មនៅក្នុងព្រៃ

នៅកន្លែងជាច្រើន កសិករកាប់ព្រៃយកដីមួយក្បាលដើម្បីដាំដំណាំ ដោយមិនប៉ះពាល់ព្រៃឈើដែលនៅសល់ទេ។ ពួកគេធ្វើកសិកម្មនៅលើដីនេះរហូតទាល់តែរុក្ខជាតិតូចៗ( ដូចជាស្មៅ )ចាប់ផ្តើមដុះរំខានដំណាំ។ បន្ទាប់មកពួកគេក៏ទៅកាប់ឆ្ការយកដីមួយក្បាលទៀត ហើយដើមឈើក៏ដុះនិងបង្កើនជីជាតិដីឡើងវិញនៅលើក្បាលដីចាស់។ វិធីនេះជួនកាលហៅថា "ការកាប់រួចដុត"។

"ការកាប់រួចដុត" ត្រូវបានអនុវត្តរាប់ពាន់ឆ្នាំមកហើយ។ ប៉ុន្តែនៅពេលចំនួនប្រជាជនកើនឡើង ហើយតាំងទីលំនៅនៅកន្លែងថ្មីៗ, ចំនួនព្រៃឈើសម្រាប់ការធ្វើកសិកម្មបែបនេះក៏ត្រូវបានកាត់បន្ថយ។ ហើយដីដែលធ្វើកសិកម្មរួច ក៏មិនមានគ្រប់គ្រាន់ឲ្យដើមឈើដុះឡើងវិញដែរ។ "ការកាប់រួចដុត" បានក្លាយជាគ្មានស្ថិរភាព សម្រាប់ទាំងកសិករនិងព្រៃឈើ។ សហគមន៍ដែលធ្វើកសិកម្មនៅក្នុងតំបន់ព្រៃឈើ អាចទទួលបានលទ្ធផលល្អប្រសើរនិងថែរក្សាទីតាំងនៅលើដីរបស់ខ្លួនបានយូរអង្វែង ប្រសិនបើពួកគេប្រើប្រាស់មធ្យោបាយកសិកម្មដែលមានស្ថិរភាព( មើលជំពូក15 )។

## ការការពារព្រៃឈើ និងការចិញ្ចឹមជីវិត

នៅក្នុងតំបន់ព្រៃអាជ្រាប្រ៉ាដេស នៃប្រទេសឥណ្ឌា អ្នកភូមិកាប់ឆ្ការព្រៃឈើយកដីច្រើនក្បាលតូចៗដើម្បីដាំដំណាំ។ ប៉ុន្តែប៉ុន្មានខែក្រោយមក នៅពេលដីរបស់ពួកគេផ្តល់អាហារតិចតួច ការចិញ្ចឹមជីវិតរបស់អ្នកភូមិ ក៏ពឹងផ្អែកលើអ្វីៗដែលដុះក្នុងព្រៃ។ អ្នកភូមិខ្លះរកឱសសម្រាប់លក់ ឯអ្នកខ្លះទៀតរកឈើធ្វើជាវត្ថុប្រើប្រាស់ផ្សេងៗសម្រាប់លក់។ វិធីដែលអនុញ្ញាតឲ្យអ្នកភូមិប្រើប្រាស់ធនធានព្រៃឈើ គឺត្រូវបានគ្រប់គ្រងដោយក្រុមមួយចំនួន ហៅថា "គណៈកម្មការព្រៃឈើប្រចាំសហគមន៍"។

នៅពេលគណៈកម្មការព្រៃឈើមើលឃើញថាមានតំបន់ខ្លះកំពុងត្រូវបានបំផ្លាញដោយការប្រើប្រាស់លើសលុប ពួកគេក៏បង្កើតច្បាប់ថ្មីដើម្បីកាត់បន្ថយបរិមាណឈើដែលផ្តល់ឲ្យអ្នកភូមិ។ ច្បាប់ទាំងនេះតឹងតែងណាស់ ហើយការចិញ្ចឹមជីវិតរបស់ប្រជាជនជាច្រើនបានទទួលការគំរាមកំហែង។ ប្រជាជនដែលចិញ្ចឹមជីវិតដោយការលក់ឱសនិងប្រដាប់ប្រដារឈើ លែងមានប្រាក់ចំណូលនេះទៀតហើយ។ ក្នុងខែដែលខ្វះខាតអាហារ គ្រួសារទាំងនេះរងគ្រោះជាខ្លាំង។

សមាជិកទាំងឡាយនៃគណៈកម្មការព្រៃឈើ គឺចេញមកពីសហគមន៍ដូចគ្នា ដូច្នេះពួកគេមានបំណងស្វែងរកដំណោះស្រាយមួយដែលធានាថានឹងគ្មានសមាជិកសហគមន៍ណាម្នាក់មានភាពអត់ឃ្លាន ប៉ុន្តែនៅតែការពារព្រៃដដែល។ បន្ទាប់ពីការប្រជុំជាច្រើនលើក ដំណោះស្រាយត្រូវបានរកឃើញ។ ជំនួសឲ្យការកែប្រែច្បាប់ព្រៃឈើ គណៈកម្មការព្រៃឈើបានជួយកែលម្អដីកសិកម្មរបស់អ្នកភូមិ ដោយការសាងសង់របាំងវ័ណ្ឌវង់ ដើម្បីពន្យឺតល្បឿនទឹកហូរនិងបង្ការសំណឹកដី។ របៀបនេះនឹងធ្វើឲ្យដីកាន់តែមានជីជាតិនិងផ្តល់ទឹកកាន់តែច្រើនសម្រាប់ដំណាំ ដូច្នេះកសិដ្ឋាននឹងមានផលិតភាពខ្ពស់ ហើយនឹងមានអាហារបន្ថែមសម្រាប់មនុស្សគ្រប់គ្នាដោយមិនបង្កគ្រោះថ្នាក់ដល់ព្រៃឈើ។



## អេកូទេសចរណ៍



អេកូទេសចរណ៍ដែលត្រូវបានគ្រប់គ្រងដោយយកចិត្តទុកដាក់ អាចការពារព្រៃឈើបាន។

អេកូទេសចរណ៍គឺជាវិធីរកប្រាក់ពីភ្ញៀវដែលមកទស្សនាកន្លែងមួយដែលមានទេសភាពធម្មជាតិស្រស់ស្អាត ឬមកស្វែងយល់អំពីរុក្ខជាតិនិងសត្វដែលរស់នៅតំបន់មួយ។ គម្រោងអេកូទេសចរណ៍ខ្លះ គ្រាន់តែនាំភ្ញៀវឲ្យមកទទួលអារម្មណ៍រីករាយជាមួយសម្រស់ធម្មជាតិប៉ុណ្ណោះ។ គម្រោងខ្លះទៀត អញ្ជើញភ្ញៀវឲ្យមករស់នៅជាមួយប្រជាជនក្នុងសហគមន៍ដើម្បីស្វែងយល់ពីការការពារបរិស្ថាន។ ក៏មានគម្រោងខ្លះទៀត អញ្ជើញពួកទេសចរឲ្យមកបំពេញការងារយ៉ាងសកម្មក្នុងគម្រោងការពារបរិស្ថានតែម្តង។

អេកូទេសចរណ៍គឺជាវិធីល្អមួយដើម្បីឲ្យសហគមន៍តំបន់ព្រៃឈើ អាចរកប្រាក់ចំណូល។ ប៉ុន្តែការចាប់ផ្តើម និងដំណើរការគម្រោងមួយ ត្រូវការប្រាក់ច្រើន និងត្រូវការការរៀបចំផែនការយ៉ាងប្រុងប្រយ័ត្ន។ ពួកទេសចរត្រូវការអាហារ, ជាសុក, ផ្ទះសំណាក់, អ្នកនាំផ្លូវ, និងការអត់ធ្មត់ច្រើនក្នុងការសម្របខ្លួនជាមួយវប្បធម៌ដែលខុសគ្នា។ ពួកគេអាចជួបគ្រោះថ្នាក់ ឬត្រូវការការថែទាំសុខភាព។ ការទាក់ទាញទេសចរឲ្យមកទស្សនាកន្លែងមួយ ត្រូវការការផ្សាយពាណិជ្ជកម្មក្នុងទស្សនាវដ្តី ឬលើអ៊ីនធឺនែត, បោះពុម្ពខិត្តប័ណ្ណ, និងទម្រង់ដទៃទៀតនៃការផ្សព្វផ្សាយ។

គម្រោងអេកូទេសចរណ៍ត្រូវតែមានការរៀបចំចាត់ចែងយ៉ាងប្រុងប្រយ័ត្ន ដើម្បីឲ្យប្រាក់ចំណូលអាចផ្តល់ផលប្រយោជន៍ដល់សហគមន៍ មិនមែនសម្រាប់តែទីភ្នាក់ងារឬពាណិជ្ជកម្មខាងក្រៅ ឬគ្រួសារក្នុងតំបន់មួយភាគតូចប៉ុណ្ណោះទេ។ ជាញឹកញាប់គម្រោងអេកូទេសចរណ៍ដែលមានជោគជ័យ តែងតែកំណត់ចំនួនទេសចរដែលមកទស្សនា ដើម្បីកុំឲ្យមានសម្ពាធខ្លាំងទៅលើសហគមន៍ និងការបំផ្លាញច្រើនទៅលើបរិស្ថាន។

## ផលិតផលមិនមែនឈើ

ផលិតផលមិនមែនឈើ គឺជាអ្វីៗទាំងអស់ក្រៅពីឈើ ដែលអាចយកនិងលក់បានដោយមិនបំផ្លាញព្រៃឈើ។ ផលិតផលនេះមានដូចជា គ្រាប់ផ្លែឈើ, ផ្លែឈើ, រុក្ខជាតិឱសថ, និងវល្លិ។ សហគមន៍ទាំងឡាយដែលមានជោគជ័យក្នុងការលក់ផលិតផលមិនមែនឈើ បានរកឃើញថាជាការសំខាន់គឺត្រូវធ្វើតាមការណែនាំទាំងនេះ

- បង្កើតច្បាប់ច្បាស់លាស់ថាតើអ្នកណាអាចប្រមូលផលនិងលក់ផលិតផលបាន និងថាតើគួរប្រមូលផលឲ្យបានល្អបំផុតក្នុងវិធីដែលមានស្ថិរភាពយ៉ាងដូចម្តេច។ នៅពេលផលិតផលមួយទទួលជោគជ័យ វាមានគ្រោះថ្នាក់ពីការប្រមូលផលច្រើនពេក។ ត្រូវប្រមូលផលល្មមតែគ្រប់គ្រាន់អាចឲ្យវាបន្តដុះឡើងមកវិញបាន។
- ស្វែងរកឬបង្កើតទីផ្សារសម្រាប់ផលិតផល។ គ្មានហេតុផលណាដែលត្រូវប្រមូលផលឡើយ បើមិនអាចលក់ដាច់ ឬគ្មានគេប្រើ។

## ការប្រមូលឱសថពីព្រៃឈើ



នៅតំបន់ក្បែរឆ្នេរបិនហ្គល(Bengal)នៃប្រទេសឥណ្ឌា ប្រជាជនជាច្រើនតែងតែទៅរកគ្រូព្យាបាលបែបបុរាណនៅពេលមានជំងឺ។ គ្រូព្យាបាលទាំងនេះផលិតឱសថពីរុក្ខជាតិដែលប្រមូលពីក្នុងព្រៃ។ ថ្ងៃមួយ មនុស្សមួយក្រុមពីអង្គការមិនមែនរដ្ឋាភិបាលមួយ បានមកដល់ភូមិនេះដើម្បីជួយប្រជាជនឲ្យរកប្រាក់តាមរយៈការប្រមូលឱសថរុក្ខជាតិទាំងនេះ រួចលក់វានៅទីក្រុង។ តាមរយៈការប្រើប្រាស់អង្គការរបស់ខ្លួនដើម្បីលក់ឱសថទាំងនេះ ពួកគេបានជួយសហគមន៍ឲ្យរកប្រាក់ចំណូលពីព្រៃឈើដោយមិនចាំបាច់កាប់ដើមឈើ។

អ្នកភូមិសប្បាយរីករាយណាស់នៅពេលមានវិធីថ្មីក្នុងការរកប្រាក់ ហើយប្រជាជនជាច្រើនចាប់ផ្តើមប្រមូលនិងលក់រុក្ខជាតិឱសថ។ ប៉ុន្តែពួកគេមិនបានសួរនាំគ្រូបុរាណថាគួរប្រមូលរុក្ខជាតិទាំងនេះដោយរបៀបណាដែលមិនបំផ្លាញវា ហើយពួកគេក៏មិនបានយកចិត្តទុកដាក់ថាខ្លួនបានប្រមូលឱសថច្រើនប៉ុនណាដែរ។

ដោយក្តីត្រេកអរនឹងការរកប្រាក់ អ្នកភូមិខ្លះបានបង្កគ្រោះថ្នាក់ដល់ដើមឈើដែលពួកគេប្រមូល។ ជំនួសឲ្យការជីកយកឫសឈើតិចតួចនៅជុំវិញដើមឈើ ប្រជាជនបែរជាកាប់រំលំដើមឈើទាំងមូលតែម្តង។ ក្នុងរយៈពេលដ៏ខ្លី រុក្ខជាតិឱសថបានបាត់បង់ពីព្រៃឈើស្ទើរតែទាំងស្រុង។ កត្តានេះធ្វើឲ្យគ្រូបុរាណលែងមានឱសថសម្រាប់ព្យាបាលទៀត។ ដូច្នេះអ្នកភូមិត្រូវចំណាយប្រាក់យ៉ាងច្រើនដើម្បីទិញថ្នាំពីឱសថស្ថាននៅពេលឈឺ។ នៅចុងបញ្ចប់ ទាំងសុខភាពមនុស្សទាំងសុខភាពព្រៃឈើ បានរងគ្រោះដោយសារការប្រមូលរុក្ខជាតិដែលមិនបានគិតពីអនាគត។

# ការកាប់បំផ្លាញព្រៃឈើ

ព្រៃឈើភាគច្រើនត្រូវបានបំផ្លាញដោយក្រុមហ៊ុនកាប់ឈើ និងសាជីវកម្មដទៃទៀតដែលរកប្រាក់ចំណូលពីការប្រើប្រាស់ធនធានដោយគ្មានស្ថិរភាព។ នៅពេលបំផ្លាញព្រៃឈើមួយកន្លែងហើយ ក្រុមហ៊ុនធំៗគ្រាន់តប្ដូរទៅកាប់ព្រៃឈើនៅកន្លែងមួយទៀតយ៉ាងងាយ។ ប៉ុន្តែប្រជាជនដែលរស់នៅក្បែរឬនៅក្នុងតំបន់ព្រៃឈើដែលបានបំផ្លាញនេះ ជាទូទៅគ្មានកន្លែងដទៃដែលត្រូវផ្លាស់ទីលំនៅទេ។

ប្រជាជនដែលមិនរស់នៅក្នុងតំបន់ព្រៃឈើដោយផ្ទាល់ ក៏នៅតែត្រូវការប្រើប្រាស់ផលិតផលព្រៃឈើយ៉ាងច្រើនដែរ ដូចជាសៀវភៅនិងកាសែត, សម្ភារៈសំណង់, អាហារ ដូចជាសាច់គោ សណ្តែកសៀង និងប្រេងដូងដែលយកពីព្រៃ, និងជាតិរ៉ែដែលជីកពីក្រោមដើមឈើ។ កម្រមានប្រជាជនណាពិចារណាអំពីតម្រូវការនៃការដាំដើមឈើឡើងវិញនៅពេលកាប់ប្រើរួចហើយទេ។

## តើព្រៃឈើត្រូវបានកាប់បន្ថយនិងកាប់បំផ្លាញដោយរបៀបណា

ប្រសិនបើធនធានព្រៃឈើមិនត្រូវបានប្រើប្រាស់និងចាត់ចែងក្នុងវិធីមួយដែលអនុញ្ញាតឲ្យវាដុះឡើងវិញទេ ព្រៃឈើទាំងអស់របស់យើងនឹងរលាយបាត់ក្នុងពេលឆាប់ៗនេះ។ មូលហេតុនៃការបំផ្លាញព្រៃឈើក្នុងទ្រង់ទ្រាយធំ រួមមាន :

- **ការកាប់បោសសម្អាត** ( នៅពេលដើមឈើស្ទើរតែទាំងអស់នៅក្នុងតំបន់មួយត្រូវបានកាប់ធ្វើជាឈើអារ ) ធ្វើឲ្យមានសំណឹកដី, បំផ្លាញសត្វព្រៃ, និងចាក់បំពេញផ្លូវទឹកដោយល្បាប់។
- **ការធ្វើកសិកម្មទំនើប** កសិដ្ឋានចិញ្ចឹមគោ និង**ចម្ការបណ្តុះកូនឈើ** ច្រើនតែពាក់ព័ន្ធនឹងការកាប់ឆ្ការព្រៃឈើ។
- **កសិដ្ឋានចិញ្ចឹមបង្កង**ត្រូវបានសាងសង់ដោយការកាប់ដើមកោងកាងនៅព្រៃលិចទឹក និងនៅព្រៃនៅតំបន់ឆ្នេរ ដែលជាញឹកញាប់ធ្វើឲ្យអ្នករកត្រីតូចតាចបាត់បង់មុខរបរ, ធ្វើឲ្យកខ្វក់ទឹក, និងនាំឲ្យមានជំងឺ ភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភកាន់តែច្រើន។
- **រោងម៉ាស៊ីនផលិតក្រដាស** បន្សល់កាកសំណល់ពុលដែលធ្វើឲ្យដី ទឹក និងខ្យល់ ក្លាយជាកខ្វក់។
- **ក្រុមហ៊ុនរុករករ៉ែ ប្រេង និងឧស្ម័ន** កាប់ព្រៃឈើ និងបន្សល់កាកសំណល់ពុលដែលធ្វើឲ្យដី ទឹក និងខ្យល់ ក្លាយជាកខ្វក់។
- **គម្រោងទំនប់ធំៗ**ធ្វើឲ្យលិចតំបន់ព្រៃឈើយ៉ាងធំ។ ប្រជាជនដែលត្រូវបានជម្លៀសចេញពីកន្លែងសង់ទំនប់ ក៏ទៅកាប់ព្រៃឈើបន្ថែមទៀតដើម្បីធ្វើផ្ទះនិងចម្ការថ្មីៗ។

**នៅពេលព្រៃឈើក្លាយទៅជាផលិតផលដែលអាចលក់និងទិញបាន សាជីវកម្ម និងរដ្ឋាភិបាលកម្រគិតពិចារណាលើផលប៉ះពាល់ដល់សុខភាពនិងសុខុមាលភាពរបស់ប្រជាជនណាស់។**



# ជម្លោះព្រៃឈើ

ដោយហេតុថាធនធានព្រៃឈើមានកំណត់ ជម្លោះតែងតែកើតឡើងរវាងប្រជាជនដែលត្រូវការប្រើប្រាស់ធនធានព្រៃឈើតាមវិធីផ្សេងៗគ្នា។ ជម្លោះក៏អាចកើតឡើងផងដែររវាងសហគមន៍ក្នុងស្រុកដែលពឹងផ្អែកលើព្រៃឈើ និងឧស្សាហកម្មក្រៅសហគមន៍ដែលចង់បានធនធានព្រៃឈើ។

## ល្ខោនសង្គម

ល្ខោនសង្គមគឺជាវិធីមួយដែលប្រើប្រាស់រោងល្ខោនដើម្បីជួយប្រជាជនឲ្យពិចារណាអំពីជម្លោះ និងមូលហេតុនៃជម្លោះទាំងនោះ។ ល្ខោនសង្គមក៏អាចជួយប្រជាជនឲ្យរិះរកលទ្ធភាពផ្សេងៗ ដើម្បីចាត់វិធានការនិងធ្វើការផ្លាស់ប្តូរ។ (មើលទំព័រ17សម្រាប់ព័ត៌មានបន្ថែមអំពីល្ខោនសង្គម និងការសម្តែងតួ។ ជាបន្ថែមសូមមើលសៀវភៅមួយរបស់អង្គការហេស្ពើរៀនដែលមានចំណងជើងថា *ការជួយបុគ្គលិកសុខាភិបាលឲ្យរៀន*)។

1. **បែងចែកប្រជាជនជាក្រុមតូចៗ**ដែលមានគ្នាប្រមាណ៥នាក់ រួចផ្តល់ឲ្យក្រុមនីមួយៗនូវសេចក្តីណែនាំខ្លីមួយអំពីស្ថានភាពដែលអាចឈានដល់ជម្លោះធនធានព្រៃឈើ។ បង្កើតស្ថានភាពដោយខ្លួនឯងដែលប្រជាជនអាចជឿបាន ប៉ុន្តែចៀសវាងស្ថានភាពដែលកើតឡើងក្នុងសហគមន៍នេះព្រោះវាអាចធ្វើឲ្យពួកគេអាម៉ាស់ឬខឹងសម្បារ។ ការសម្តែងនេះនឹងកាន់តែដូចការពិត ប្រសិនបើអ្នកចូលរួមតែងខ្លួននិងរៀបឆាកយ៉ាងសាមញ្ញៗនៅពេលសម្តែង។

2. **ប្រាប់ក្រុមនីមួយៗ**ឲ្យប្រើពេលវេលា១៥ទៅ២០នាទីក្នុងការរៀបចំការសម្តែងល្ខោនសង្គមមួយដែលមានរយៈពេល៥នាទី។ លើកទឹកចិត្តឲ្យមនុស្សគ្រប់គ្នាសម្តែងក្នុងផ្នែកណាមួយ។ ក្រុមនីមួយៗបង្ហាញពីការសម្តែងរបស់ខ្លួនឲ្យអ្នកចូលរួមដទៃទៀតទស្សនា។ បន្ទាប់ពីបញ្ចប់ល្ខោនសង្គមនីមួយៗ អ្នកចូលរួមត្រូវពិភាក្សាគ្នាអំពីជម្លោះក្នុងសហគមន៍ ដែលអាចនាំទៅរកដំណោះស្រាយ។ ឬមួយអ្នកអាចរង់ចាំទាល់តែក្រុមទាំងអស់បានសម្តែងចប់ រួចទើបពិភាក្សារួមគ្នាទាំងអស់តែម្តងក៏បាន។



3. **តើអ្នកមានអារម្មណ៍ដូចម្តេច?** បន្ទាប់ពីសម្តែងល្ខោនសង្គម និងមុនពេលចាប់ផ្តើមការពិភាក្សា (មើលទំព័រ189) ចូរសួរអ្នកចូលរួមម្នាក់ៗថាពួកគេមានអារម្មណ៍យ៉ាងដូចម្តេចក្នុងការសម្តែងតួរបស់ខ្លួន។ សួរអ្នកទស្សនាថាតើពួកគេមានអារម្មណ៍បែបណាក្នុងអំឡុងពេលសម្តែងនីមួយៗ និងថាតើតួអង្គសម្តែងបានធ្វើឲ្យពួកគេមានអារម្មណ៍បែបណាចំពោះជម្លោះដែលកើតឡើង។



**ល្ខោនសង្គម**(ត)

ជ្រើសរើសសាច់រឿងខាងក្រោមមួយចំនួនដើម្បីបង្កើតជាល្ខោនសង្គមស្តីអំពីជម្លោះព្រៃឈើ។ ឬមួយបង្កើតល្ខោនសង្គមដោយខ្លួនឯង ដោយផ្អែកលើជម្លោះជាក់ស្តែងនៅក្នុងសហគមន៍របស់អ្នក។



**ស្ថានភាពទី១។** តួអង្គ : បុរស និងសត្វគោ, អ្នកដើររកឱសថរុក្ខជាតិ, អ្នកចូលរួមក្នុងការប្រជុំ។

បន្ទាប់ពីបានចាកចេញពីសហគមន៍ច្រើនឆ្នាំមក ហើយ បុរសម្នាក់បានត្រឡប់មកវិញដោយមានសត្វគោ១០ក្បាល រួចក៏ចាប់ផ្តើមឲ្យពួកវាស៊ីស្មៅនៅក្នុងព្រៃសហគមន៍។ នៅពេលប្រជាជនដទៃទៀតទៅដើររកឱសថនិងស្បូវ ពួកគេឃើញថាសត្វគោទាំងនោះស៊ីស្មៅនិងរុក្ខជាតិជាច្រើនដែលធ្វើឲ្យនៅសល់រុក្ខជាតិតិចតួចសម្រាប់ពួកគេ។ ពួកគេបានកោះហៅប្រជុំពិភាក្សាបញ្ហានេះ។ បុរសចិញ្ចឹមគោអះអាងថាគាត់មានសិទ្ធិឲ្យគោស៊ីស្មៅ ទោះជាវាស៊ីអស់ប៉ុន្មានក៏ដោយ។ អ្នកដទៃមិនយល់ស្រប។ តើមានអ្វីកើតឡើងតទៅទៀត?



**ស្ថានភាពទី២។** តួអង្គ : បុរសវ័យក្មេងម្នាក់កាប់ដើមឈើ, មន្ត្រីរាជការ, ស្ត្រីរកឧស។

បុរសវ័យក្មេងប៉ុន្មាននាក់កំពុងកាប់ដើមឈើនៅលើដីមួយក្នុងសង្កាត់ដោយគ្មានការអនុញ្ញាត រួចលក់ឈើអាររួចទៅឲ្យមន្ត្រីរាជការដែលដឹកឈើទាំងនោះចេញដោយប្រើរថយន្តធំ។ ស្ត្រីម្នាក់ធ្វើដំណើរទៅកន្លែងដែលគាត់តែងតែរកឧស ហើយឃើញបុរសវ័យក្មេងទាំងនោះកំពុងកាប់ដើមឈើ។ បុរសម្នាក់ក្នុងនោះគឺជាកូនប្រុសរបស់គាត់។ គាត់ត្រឡប់ទៅសហគមន៍វិញ រួចប្រាប់ម្តាយរបស់បុរសឯទៀត។ ស្អែកឡើងស្ត្រីទាំងនេះទៅក្នុងព្រៃដើម្បីប្រាប់កូនៗរបស់គាត់ឲ្យឈប់កាប់ដើមឈើ។ កូនរបស់ស្ត្រីទី១និយាយថា គាត់ត្រូវការប្រាក់ពីការលក់ឈើនេះដើម្បីទិញថ្នាំឲ្យកូនស្រីរបស់គាត់ដែលត្រូវជាចៅរបស់ស្ត្រីនេះ។ តើមានអ្វីកើតឡើងតទៅទៀត?

**ស្ថានភាពទី៣។** តួអង្គ : ពួកអ្នកភូមិមានពូថៅ និងសត្វគោ, ពួកអាជ្ញាធរខេត្តមានម៉ាស៊ីនអារឈើ និងរថយន្តដឹក, មន្ត្រីប្រឹក្សាភូមិ។



ជាច្រើនជំនាន់មកហើយ អ្នកភូមិតែងតែកាប់ឈើដោយប្រើពូថៅ រួចប្រើគោឲ្យទាញឈើកាប់រួច។ ឥឡូវនេះមានបុរសមួយក្រុមមកពីអាជ្ញាធរខេត្តប្រដាប់ដោយម៉ាស៊ីនអារឈើ កំពុងកាប់ឈើក្នុងព្រៃ ហើយនិយាយថាព្រៃឈើគឺជាទ្រព្យសម្បត្តិរដ្ឋ។ ថ្ងៃមួយបុរសទាំងនេះបានយកម៉ាស៊ីនឈូសដី និងឧបករណ៍ធ្ងន់ៗ។ ពួកគេចង់ធ្វើផ្លូវទៅក្នុងព្រៃដើម្បីអាចដឹកឈើធំៗបាន។ បុរស ក្នុងភូមិមួយក្រុមបានទៅក្នុងព្រៃដើម្បីប្រឈមមុខនឹងពួកគេ។ តើមានអ្វីកើតឡើងតទៅទៀត?

**ល្ខោនសង្គម(ត)**




### 4 ពិភាក្សាអំពីល្ខោនសង្គមនីមួយៗ។

ប្រាប់ឲ្យអ្នកសម្តែងប្រមូលប្រដាប់គុបតែងឆាកទុកនៅមួយដុំនៅខាងមុខបន្ទប់ រួចត្រឡប់ចូលរួមក្នុងក្រុមវិញ។ បន្ទាប់មកសួរសំណួរមួយចំនួនដល់ពួកគេដើម្បីជួយក្រុមទាំងមូលឲ្យ :

- និយាយប្រាប់ថាអ្វីខ្លះបានកើតឡើងនៅក្នុងល្ខោនសង្គម។
- កំណត់រកតួអង្គណាខ្លះដែលជាអ្នកបង្កជម្លោះ។
- កំណត់រកតម្រូវការខុសៗគ្នាដែលជាមូលហេតុឫសគល់នៃជម្លោះ។
- ផ្តល់យោបល់អំពីវិធីដោះស្រាយជម្លោះឲ្យបានយូរអង្វែង។

ធ្វើឡើងវិញនូវដំណើរការនេះចំពោះល្ខោនសង្គមនីមួយៗ។ អ្នកសម្របសម្រួលអាចសរសេរពីគំនិតសំខាន់ៗនៅលើក្រដាសធំៗឬក្តារខៀន។

| | |
|---|---|
| *សំណួរ : តើអ្វីជាមូលហេតុនៃជម្លោះ?* | *ចម្លើយ : បុរសម្នាក់ចង់ចិញ្ចឹមគោ ប៉ុន្តែវាបំផ្លាញព្រៃ។* |
| *សំណួរ : ហេតុអ្វីបានជាបុរសនេះគិតថាគាត់មានសិទ្ធិចិញ្ចឹមគោនៅក្នុងព្រៃ?* | *ចម្លើយ : គ្មានកិច្ចព្រមព្រៀងថាអ្នកណាអាចប្រើប្រាស់ព្រៃឈើ និងប្រើក្នុងបំណងអ្វីទេ។* |
| *សំណួរ : តើការបំផ្លាញព្រៃឈើប៉ះពាល់សហគមន៍យ៉ាងដូចម្តេចខ្លះ?* | *ចម្លើយ : លែងមានឱសថនិងស្បូវ។* |
| *សំណួរ : ដូច្នេះតើតម្រូវការអ្វីខ្លះដែលមាននៅក្នុងជម្លោះ?* | *ចម្លើយ : តម្រូវការប្រើប្រាស់ផលិតផលព្រៃឈើ និងតម្រូវការចិញ្ចឹមគោ។* |
| *សំណួរ : តើមានវិធីណាដែលអាចបំពេញតម្រូវការទាំងពីរនេះដែរឬទេ?* | *ចម្លើយ : គាត់អាចចិញ្ចឹមគោឲ្យស៊ីស្មៅនៅកន្លែងដែលគ្មានរុក្ខជាតិដែលសហគមន៍ត្រូវការ។* |
| | *ចម្លើយ : ម្ចាស់គោអាចសង់របង។* |
| | *ចម្លើយ : ម្ចាស់គោអាចបោះបង់សិទ្ធិប្រមូលផលិតផលព្រៃឈើរបស់ខ្លួន ដើម្បីប្តូរយកសិទ្ធិក្នុងការចិញ្ចឹមគោ បន្ទាប់មកគាត់អាចទិញផលិតផលទាំងនោះពីប្រជាជនវិញ។* |



ប្រសិនបើការពិភាក្សាបង្កើតឲ្យមានការខ្វែងគំនិតគ្នាយ៉ាងច្រើន នោះជាការសំខាន់គឺត្រូវបញ្ចប់សកម្មភាពក្នុងវិធីមួយដែលធ្វើឲ្យពួកគេរួមគ្នា។ ឧទាហរណ៍ ការច្រៀងចម្រៀងរួមគ្នា ឬធ្វើសកម្មភាពដែលសហការគ្នា អាចជួយប្រជាជនឲ្យបញ្ចប់សកម្មភាពជាមួយអារម្មណ៍ប្រសើរ។

# ការប្រើប្រាស់ព្រៃឈើប្រកបដោយស្ថិរភាព

ការគ្រប់គ្រងព្រៃឈើប្រកបដោយស្ថិរភាព មានន័យថាជាការប្រើប្រាស់ និងថែរក្សាព្រៃឈើក្នុងរបៀបដែលបំពេញតម្រូវការប្រចាំថ្ងៃ ខណៈដែលការពារព្រៃឈើសម្រាប់អនាគតផងដែរ។ មធ្យោបាយស្ថិរភាពមិនមែនដូចៗគ្នានៅគ្រប់ទីកន្លែងទេ។ សហគមន៍នីមួយៗចាំបាច់ត្រូវស្វែងយល់ថាអ្វីដែលមានប្រសិទ្ធភាពបំផុតសម្រាប់ពួកគេនិងសម្រាប់ព្រៃឈើរបស់គេ។

ការរៀបចំផែនការគ្រប់គ្រងព្រៃឈើប្រកបដោយស្ថិរភាព អាចជួយសហគមន៍ឲ្យសម្រេចថាអ្វីដែលមានប្រសិទ្ធភាពបំផុតក្នុងការប្រើប្រាស់ព្រៃឈើរបស់ខ្លួន។ វាក៏ជួយក្នុងការប្រឆាំងនឹងការគំរាមកំហែងពីឧស្សាហកម្មឬអាជ្ញាធរដែលចង់ដណ្ដើមព្រៃឈើ។ ជួនកាលអ្នកអាចលក់ផលិតផលព្រៃឈើបានតម្លៃកាន់តែល្អ ប្រសិនបើអ្នកអាចបង្ហាញថាផលិតផលទាំងនេះត្រូវបានបង្កើតឡើងយ៉ាងមានស្ថិរភាព។ ប៉ុន្តែផ្នែកដែលសំខាន់បំផុតនៅក្នុងផែនការគ្រប់គ្រងព្រៃឈើប្រកបដោយស្ថិរភាព គឺថាវាជួយធ្វើឲ្យប្រជាជនក្នុងតំបន់សហការគ្នាក្នុងការប្រើប្រាស់និងការពារព្រៃឈើ។

វិធីមួយចំនួនក្នុងការប្រើប្រាស់និងការពារព្រៃឈើក្នុងពេលតែមួយ មានដូចជា :

- **ការកាប់វល្លិ រុក្ខជាតិ និងដើមឈើឲ្យស្តើង** ដើម្បីឲ្យពន្លឺថ្ងៃចូលក្នុងព្រៃ ដូច្នេះរុក្ខជាតិដែលអ្នកចង់បានអាចលូតលាស់។



ការកាប់ដើមឈើឲ្យស្តើង មានន័យថាជាការកាប់ដើមឈើជាក់លាក់មួយចំនួន ដើម្បីឲ្យដើមឈើដែលនៅសល់អាចលូតលាស់បានកាន់តែធំ និងកាន់តែមានសុខភាពល្អ។

- **ការដាំឈើបង្កើនគុណភាព** មានន័យថាជាការដាំដើមឈើឬរុក្ខជាតិថ្មីៗនៅក្រោមដើមឈើចាស់ៗ ឬនៅកន្លែងកាប់ឆ្ការតូចៗ នៅពេលដែលដើមឈើទាំងនេះមិនដុះឡើងមកវិញដោយខ្លួនឯង។
- **ការដាំឡើងវិញក្រោយពេលកាប់រួច** គឺជាវិធីមួយដើម្បីធានាថានឹងមានដើមឈើនិងគ្រាប់ពូជថ្មីៗជំនួសដើមឈើចាស់ៗដែលបានកាប់។
- **ការដុតភ្លើងដែលមានការគ្រប់គ្រង** អាចកាត់បន្ថយគុម្ពោតដែលដុះនៅក្រោមដើមឈើ។ ធ្វើដូច្នេះធ្វើឲ្យវាបញ្ចេញសារធាតុចិញ្ចឹមទៅក្នុងដី និងសម្លាប់សត្វល្អិតដែលអាចបង្កគ្រោះថ្នាក់ដល់ដើមឈើ។ ការដុតភ្លើងដែលមានការគ្រប់គ្រង ត្រូវការការរៀបចំផែនការយ៉ាងប្រុងប្រយ័ត្ន ព្រោះភ្លើងអាចឆាបឆេះមិនអាចគ្រប់គ្រងបាន។
- **ការកាប់ឈើដោយជ្រើសរើស** មានន័យថាជាការកាប់តែដើមឈើខ្លះ ខណៈដែលថែរក្សាដើមឈើក្មេងៗនិងដើមឈើចាស់ៗដែលល្អដើម្បីទប់ដីនិងផ្តល់គ្រាប់ពូជសម្រាប់អនាគត។



ការកាប់ឈើដោយជ្រើសរើស ការពារដើមឈើខ្លះសម្រាប់អនាគត អនុញ្ញាតឲ្យព្រៃឈើបន្តលូតលាស់។

- **ការប្រមូលនិងលក់ផលិតផលមិនមែនឈើ** ជាជាងការលក់ឈើ គឺជាវិធីមួយក្នុងការថែរក្សាព្រៃឈើ ខណៈដែលរកប្រាក់ចំណូលផងដែរ។
- **ការផ្តល់ប្រាក់**ដល់អ្នកចិញ្ចឹមសត្វឲ្យដាក់សត្វឲ្យនៅក្រៅព្រៃ និងការផ្តល់ប្រាក់ដល់កសិករកុំឲ្យកាប់ដើមឈើនៅលើដីរបស់ខ្លួន អាចជួយគាំទ្រដល់ព្រៃឈើ និងបង្ការជម្លោះ។
- **ថែរក្សាផ្លូវដើររបស់សត្វព្រៃ** ធ្វើឲ្យសត្វព្រៃរស់នៅក្នុងព្រៃ និងធ្វើដំណើរក្នុងនោះ។
- **សាងសង់ចន្លោះពណ៌បៃតង** ដើមឈើលើផ្ទៃដីតូចៗ នៅក្នុងកន្លែងដែលបានកាប់ឈើស្ទើរតែអស់ទាំងស្រុងឬអស់ទាំងស្រុង គឺជាវិធីមួយជួយកែលម្អដី ទឹក និងខ្យល់ ទោះបីក្នុងទីក្រុងដែលមានមនុស្សកុះករក៏ដោយ។
- **ការជួយគាំទ្រដល់ការដុះលូតលាស់ឡើងវិញនៃព្រៃឈើ** តាមរយៈការដាក់កម្រិតលើការប្រើប្រាស់ព្រៃឈើក្នុងតំបន់ដែលបានកាប់ឈើយ៉ាងច្រើន អាចជួយព្រៃឈើឲ្យប្រសើរឡើងវិញបាន។
- **ការប្រើសត្វឲ្យទាញឈើ** ធ្វើឲ្យមានការបំផ្លាញតិចជាងម៉ាស៊ីនឈូសដីឬម៉ាស៊ីនធុន់ៗដទៃទៀត។

សត្វធ្វើឲ្យប៉ះពាល់ដីក្នុងព្រៃតិចជាងម៉ាស៊ីនទេ។



- **ការកាត់តម្រឹមសំបកឈើនិងមែកឈើ**នៃដើមឈើដែលរលំ មុននឹងអូសវាចេញពីព្រៃ ធ្វើឲ្យមិនសូវមានការបំផ្លាញដល់រុក្ខជាតិដទៃទៀត។ សំបកនិងមែកឈើក្លាយជារលួស ហើយធ្វើឲ្យដីមានជីជាតិ។
- **អេកូទេសចរណ៍**អាចរកប្រាក់ចំណូលតាមរយៈការនាំភ្ញៀវឲ្យទស្សនាសម្រស់ធម្មជាតិនៃព្រៃឈើដោយមិនចាំបាច់កាប់ដើមឈើឬបំផ្លាញបរិស្ថាន។



**មានវិធីច្រើនយ៉ាងក្នុងការប្រើប្រាស់ព្រៃឈើដោយរក្សាវាឲ្យមានសុខភាពល្អជានិច្ចសម្រាប់អនាគត។**

## ប្រើប្រាស់ចំណេះដឹងរបស់មនុស្សគ្រប់គ្នា ពិចារណាពីតម្រូវការរបស់មនុស្សគ្រប់គ្នា



សកម្មភាពនេះជួយសហគមន៍ឲ្យពិចារណាពីរបៀបប្រើប្រាស់និងថែរក្សាធនធានព្រៃឈើក្នុងវិធីដែលផលប្រយោជន៍ដល់មនុស្សគ្រប់គ្នា។ សកម្មភាពនេះអាចធ្វើឡើងជាមួយមនុស្សរហូតដល់២៥នាក់ ដោយបែងចែកជាបីក្រុមតូចៗ។ ជាការសំខាន់គឺត្រូវរាប់បញ្ចូលមនុស្សគ្រប់គ្នាដែលនឹងរងផលប៉ះពាល់ពីការសម្រេចចិត្តប្រើប្រាស់ព្រៃឈើ។

**ពេលវេលា :** ៣ទៅ៦ម៉ោង(ឬច្រើនវគ្គ ដរាបណាអ្នករក្សាទុកផែនទី)

**សម្ភារៈ :** ប៊ិច, ខ្មៅដៃ, ក្រដាសសៀវភៅ, ក្រដាសធំពផ្ទាំងដែលមានផែនទីនៃតំបន់របស់អ្នក, និងបង់ស្អិត។ អាចគូរផែនទីប្រហែលៗ ដរាបណាប្រជាជនអាចស្គាល់ថាវាបង្ហាញពីអ្វី។



❶ ផ្តល់ផែនទីមួយទៅក្រុមនីមួយៗ។ ប្រាប់មនុស្សគ្រប់គ្នាឲ្យគូររូបអំពីសកម្មភាពរបស់ខ្លួននៅក្នុងព្រៃ(កាប់ឧស ឲ្យគោស៊ីស្មៅ រកផ្លែឈើនិងរុក្ខជាតិ បរបាញ់សត្វ ។ល។) នៅលើក្រដាសសៀវភៅ។

❷ នៅក្នុងក្រុមនីមួយៗ មនុស្សគ្រប់គ្នានិយាយអំពីគំនូររបស់ខ្លួន ថាតើវាន័យដូចម្តេច។ បន្ទាប់មកមនុស្ស១ឬ២នាក់ គូររូបទាំងនេះនៅលើផែនទីដើម្បីបង្ហាញពីទីកន្លែងនិងរបៀបនៃការប្រើប្រាស់ព្រៃឈើ។

❸ បញ្ចូលក្រុមទាំងអស់ចូលគ្នាវិញដើម្បីឲ្យពិភាក្សាអំពីការបង្ហាញរបស់ផែនទីទាំងនោះ។ តើផ្នែកខ្លះនៃព្រៃឈើត្រូវបានប្រើប្រាស់ច្រើនជាងផ្នែកដទៃទៀតដែរឬទេ? តើបុរស ស្ត្រី កុមារ និងមនុស្សចាស់ ប្រើប្រាស់ព្រៃឈើតាមរបៀបខុសៗគ្នាដែរឬទេ? តើមានភាពចម្លែកខ្លះទេចំពោះវិធីដែលព្រៃឈើត្រូវបានប្រើប្រាស់?



❹ អ្នកសម្របសម្រួលដឹកនាំការពិភាក្សាអំពីសុខភាពព្រៃឈើដោយសួរសំណួរដូចនេះ : តើសព្វថ្ងៃព្រៃឈើផ្តល់ធនធានដូចកាលពីមុនដែរឬទេ? តើសត្វស្លាប សត្វព្រៃ និងរុក្ខជាតិ មានតិចជាងកាលពីមុនឬទេ? តើមានកន្លែងណាដែលបានកាប់ដើមឈើអស់ទាំងស្រុងឬទេ? តើមានអ្វីកើតឡើងនៅទីនោះ?



❺ ឲ្យមនុស្ស១ឬ២នាក់ពីក្រុមនីមួយៗ គូរសម្គាល់លើផែនទីរបស់ខ្លួនដោយប្រើពណ៌ឬនិមិត្តសញ្ញាខុសៗគ្នាដើម្បីបង្ហាញពីទីកន្លែងដែលមានព្រៃឈើល្អ មានព្រៃឈើថយចុះ ឬបាត់បង់ទាំងស្រុង។

❻ គិតអំពីតំបន់ខុសៗគ្នានៅក្នុងព្រៃ ហើយពិភាក្សាថាតើប្រជាជនចង់ឃើញមានការផ្លាស់ប្តូរអ្វីខ្លះ។ គូរឬសរសេរការផ្លាស់ប្តូរទាំងនោះនៅលើផែនទី។ នៅទំព័របន្ទាប់គឺជាសំណួរខ្លះៗដែលអាចជួយអ្នកឲ្យណែនាំការពិភាក្សា។



## រៀបចំផែនការគ្រប់គ្រងព្រៃឈើ

បន្ទាប់ពីធ្វើសកម្មភាពនៅទំព័រ១៩១ គួរពិចារណាលើសំណួរទាំងនេះ :

- **តើផលប្រយោជន៍និងធនធានអ្វីខ្លះដែលព្រៃឈើផ្តល់ឲ្យយើង?** តើដើមឈើ រុក្ខជាតិ និងសត្វអ្វីខ្លះដែលត្រូវបានប្រើប្រាស់? តើក្នុងរដូវនីមួយៗត្រូវចំណាយប្រាក់អស់ប៉ុន្មាន? តើមានតំបន់ដែលធនធានទាំងនេះលូតលាស់តិចតួចឬបានបាត់បង់ទាំងស្រុងឬទេ?
- **តើយើងជួយគាំទ្រព្រៃឈើដោយរបៀបណា?** តើសហគមន៍ដាំដើមឈើ ការពារតំបន់ជាក់លាក់ ឬមានវិធីដទៃដើម្បីធានាថាព្រៃឈើនៅមានសុខភាពល្អជានិច្ចដែរឬទេ?
- **តើផ្នែកខ្លះនៃព្រៃឈើគួរតែបានការពារមិនឲ្យប្រើប្រាស់ឬទេ?** តើការធ្វើដូចនេះនឹងប៉ះពាល់ដល់ប្រជាជនដែលប្រើប្រាស់ព្រៃក្នុងផ្នែកទាំងនោះយ៉ាងដូចម្តេច?
- **តើគួរអនុវត្តមធ្យោបាយស្ថិរភាពនៅក្នុងផ្នែកខ្លះដែរឬទេ?** តើសហគមន៍មានចំណេះដឹងអ្វីខ្លះអំពីការថែរក្សាព្រៃឈើ ដើម្បីជួយធ្វើការផ្លាស់ប្តូរទាំងនេះ?
- **តើជំនាញអ្វីខ្លះដែលយើងត្រូវការដើម្បីធ្វើឲ្យការគ្រប់គ្រងព្រៃឈើប្រកបដោយស្ថិរភាព ទទួលជោគជ័យ?** ប្រសិនបើយើងមិនមានជំនាញទាំងនោះ តើយើងអាចរៀនសូត្រវាបានទេ? តើយើងចាំបាច់ត្រូវពឹងផ្អែកលើអង្គការដទៃទៀតដែរឬទេ? តើយើងអាចបង្កើតសម្ព័ន្ធភាពរឹងមាំជាមួយអង្គការដែលទុកចិត្តយ៉ាងដូចម្តេច ដើម្បីជួយយើងឲ្យទទួលបានជំនាញនិងចំណេះដឹង?
- **តើសហគមន៍របស់យើងអាចគ្រប់គ្រងគម្រោងព្រៃឈើរបស់យើងបានយ៉ាងដូចម្តេច?** សហគមន៍ដែលមានការរៀបចំល្អ ដែលបង្ហាញពីសារច្បាស់លាស់និងខ្លាំងក្លាដល់អ្នកនៅខាងក្រៅអំពីអ្វីដែលពួកគេចង់បាន ជាទូទៅទទួលបានផលប្រយោជន៍យ៉ាងច្រើនពីគម្រោងព្រៃឈើប្រកបដោយស្ថិរភាព។
- **តើយើងនឹងនាំយកផលិតផលរបស់យើងទៅកាន់ទីផ្សារយ៉ាងដូចម្តេច?** ជាញឹកញាប់ការនាំផលិតផលទៅទីផ្សារជាតិនិងអន្តរជាតិ ត្រូវការការចំណាយប្រាក់ច្រើនជាងការលក់ផលិតផលនៅក្នុងតំបន់។ តម្លៃក្នុងតំបន់មានកម្រិតទាប ប៉ុន្តែតម្លៃលក់ក៏មានកម្រិតទាបដែរ។
- **តើផលិតផលព្រៃឈើរបស់យើងនឹងមានតម្លៃប៉ុន្មាន?** បើអ្នកមិនដឹងថានឹងទទួលបានតម្លៃសមរម្យពីផលិតផលព្រៃឈើទេ អ្នកអាចទាក់ទងអង្គការពាណិជ្ជកម្មយុត្តិធម៌(មើលផ្នែកធនធាន)បាន។
- **តើផែនការថ្មីនេះនឹងផ្តល់ការផ្លាស់ប្តូរអ្វីខ្លះ?** តើផែនការគ្រប់គ្រងថ្មីនេះនឹងដាក់កម្រិតលើលទ្ធភាពប្រជាជនក្នុងការប្រើប្រាស់ព្រៃឈើដែរឬទេ? តើសហគមន៍នឹងជួយពួកគេវិញដោយរបៀបណា?



# ភាពជាដៃគូការពារព្រៃឈើ

ការបង្កើតដៃគូយ៉ាងច្រើនជាមួយក្រុមផ្សេងៗដែលទទួលផលប្រយោជន៍ពីព្រៃឈើ ជួយធ្វើឲ្យប្រាកដថា ព្រៃឈើត្រូវបានប្រើប្រាស់ក្នុងវិធីដែលបំពេញតម្រូវការមនុស្សគ្រប់គ្នា។ ការបង្កើតដៃគូជាមួយប្រជាជននៅក្រៅសហគមន៍របស់អ្នក ក៏ជួយការពារសិទ្ធិរបស់អ្នកដែរ។

## ការធ្វើការរួមគ្នាដើម្បីការពារព្រៃទឹកភ្លៀងអាម៉ាហ្សូន

ប្រជាជនអាម៉ាហ្សានហ្កា (Amazanga) មិនមែនធ្លាប់តែរស់នៅដូចរបៀបសព្វថ្ងៃទេ។ ការកំពប់ប្រេងបានបង្ខំឲ្យពួកកុលសម្ព័ន្ធខ្វីឈូអា (Quichua) រើទីលំនៅពីដីដូនតារបស់ខ្លួននៅក្នុងព្រៃអាម៉ាហ្សូន។ នៅពេលដែលផ្ទះថ្មីៗរបស់ពួកគេទទួលការគំរាមកំហែងពីការកាប់បំផ្លាញព្រៃឈើនិងកសិកម្មទំនើប អ្នកភូមិក៏បានសម្រេចចិត្តថា ការគ្រប់គ្រងដីរបស់ខ្លួនតាមវិធីបុរាណ ដូចជាការបរបាញ់សត្វ ការរកត្រី និងការរករុក្ខជាតិដើម្បីអាហារនិងឱសថ គឺជាវិធីល្អបំផុតក្នុងការការពារដីរបស់ខ្លួន។

ប៉ុន្តែធ្វើបែបនេះទាមទារដីច្រើនជាងដីដែលពួកគេមានសព្វថ្ងៃ។ ប្រជាជនអាម៉ាហ្សានហ្កាទាមទារឲ្យរដ្ឋាភិបាលផ្តល់ដីដល់ខ្លួនដើម្បីរស់នៅដូចកាលពីបុព្វបុរសគេធ្លាប់រស់នៅ។ ពួកគេនិយាយថា "យើងមិនអាចរស់នៅលើដីមួយដុំតូចដូចទំហំប៉ុងមួយចំណិតនោះទេ។ យើងចង់បានដីនិងសិទ្ធិក្នុងការរស់នៅយ៉ាងសុខស្រួលពីព្រៃឈើ។" នៅពេលរដ្ឋាភិបាលមិនខ្វល់នឹងការទាមទាររបស់ខ្លួន ពួកគេបានសុំឲ្យក្រុមបរិស្ថានអន្តរជាតិជួយទិញដីបុព្វបុរសរបស់ខ្លួនមកឲ្យពួកគេវិញ។

អ្នកភូមិបានអញ្ជើញដៃគូអន្តរជាតិឲ្យមកថតរូបនិងថតវីដេអូពីសកម្មភាពប្រើប្រាស់ព្រៃឈើតាមវិធីបុរាណ រួចយករូបថតនិងវីដេអូទាំងនេះទៅផ្សព្វផ្សាយក្នុងប្រទេសរបស់អង្គការអន្តរជាតិទាំងនោះ។ ប៉ុន្មានឆ្នាំក្រោយមក អ្នកភូមិអាម៉ាហ្សានហ្កាបានទទួលមូលនិធិគ្រប់គ្រាន់អាចទិញដីជិត២០០០ហិកតានៅក្នុងព្រៃ។

ប៉ុន្តែការទិញដីច្រើនបែបនេះបានធ្វើឲ្យកុលសម្ព័ន្ធស៊ូអា (Shuar) ដែលរស់នៅក្បែរគ្នា មានការសង្ស័យ។ នៅពេលដែលប្រជាជនស៊ូអាទាមទារកម្មសិទ្ធិដីដែលទិញនេះ ប្រជាជនអាម៉ាហ្សានហ្កាបានយល់ថាពួកគេមានកំហុស។ ពួកគេបានបង្កើតដៃគូជាមួយអង្គការអន្តរជាតិ ប៉ុន្តែមិនបានធ្វើកិច្ចព្រមព្រៀងជាមួយអ្នកជិតខាងរបស់ខ្លួនទេ! ពួកប្រជាជនស៊ូអាមានការខឹងសម្បារយ៉ាងខ្លាំង និងគំរាមធ្វើអំពើហឹង្សា។ បន្ទាប់ពីជួបប្រជុំគ្នាច្រើនលើករួចមក ប្រជាជនអាម៉ាហ្សានហ្កា និងស៊ូអា ក៏បានយល់ព្រមចែករំលែកព្រៃឈើគ្នាដោយផ្អែកលើច្បាប់នៃការចែករំលែក។ ដោយសារពួកខ្វីឈូអានិងពួកស៊ូអាមានការយល់ដឹងប្រហាក់ប្រហែលគ្នាអំពីរបៀបប្រើប្រាស់ព្រៃឈើឲ្យបានល្អបំផុត ទើបពួកគេអាចបង្កើតសម្ព័ន្ធមិត្តជាមួយគ្នាបាន។

ពួកគេបានដាក់ដីនេះជាព្រៃឈើអភិរក្ស និងព្រមព្រៀងលើផែនការគ្រប់គ្រងព្រៃឈើដែលបង្ការការកាប់ដើមឈើនិងសាងសង់ផ្លូវ។ ដីនេះត្រូវបានប្រកាសជា "មរតករបស់កុលសម្ព័ន្ធទាំងអស់ក្នុងព្រៃអាម៉ាហ្សូន" និងការពារវាសម្រាប់មនុស្សជំនាន់ក្រោយៗ។ តាមរយៈការបង្កើតដៃគូជាមួយអ្នកនៅជិតៗនិងនៅឆ្ងាយៗ ប្រជាជនអាម៉ាហ្សានហ្កានឹងការពារព្រៃឈើរបស់ខ្លួន ថែរក្សាវប្បធម៌ និងជួយអ្នកដទៃឲ្យការពារព្រៃឈើរបស់ខ្លួន។

# ការអភិរក្សព្រៃឈើ

ការបង្កើតឧទ្យានព្រៃឈើ និងព្រៃឈើអភិរក្ស អាចជាវិធីមួយដែលទទួលការគាំទ្រពីរដ្ឋាភិបាលនិងអង្គការអន្តរជាតិក្នុងការការពារព្រៃឈើ និងលើកកម្ពស់វិស័យអេកូទេសចរណ៍។ ប៉ុន្តែជួនកាលរដ្ឋាភិបាលខ្លះនិងក្រុម**អភិរក្ស**មួយចំនួន គិតថាវិធីតែមួយគត់ក្នុងការការពារនិងអភិរក្សព្រៃឈើ គឺការហាមឃាត់មិនឲ្យមនុស្សចូល។ ក្នុងករណីជាច្រើន ការគិតបែបនេះគឺមិនត្រឹមត្រូវទេ។ ប្រជាជនដែលរស់នៅក្នុងព្រៃ ចេះដឹងពីរបៀបប្រើប្រាស់ និងថែរក្សាព្រៃឈើ។ តាមរយៈការរស់នៅក្នុងព្រៃ និងការគ្រប់គ្រងឧទ្យានព្រៃឈើនិងព្រៃឈើអភិរក្ស ប្រជាជនក្នុងតំបន់អាចការពារព្រៃឈើបានល្អជាងរដ្ឋាភិបាលឬក្រុមអភិរក្សនានា។




សហគមន៍ខ្លះនៅតែប្រើប្រាស់ធនធាននៅក្នុងព្រៃអភិរក្សដដែល ដោយធ្វើកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាល និងសហគមន៍ក្នុងតំបន់ដទៃទៀតក្នុងការគ្រប់គ្រងធនធានទាំងនេះរួមគ្នា។ នេះហៅថា "គម្រោងគ្រប់គ្រងរួមគ្នា"។

ការគ្រប់គ្រងរួមគ្នា អនុញ្ញាតឲ្យប្រជាជនបន្តប្រើប្រាស់ព្រៃឈើនិងផលិតផលព្រៃឈើតាមរបៀបបុរាណ និងប្រកបដោយស្ថិរភាព។ សហគមន៍ដែលគ្រប់គ្រងព្រៃអភិរក្ស ក៏អាចអប់រំសហគមន៍ដទៃអំពីសារសំខាន់នៃការការពារព្រៃឈើផងដែរ។

## រុក្ខសាស្ត្រដែលថែរក្សាទាំងមនុស្សនិងដើមឈើ

នៅព្រៃទឹកភ្លៀងអាម៉ាហ្សូនក្នុងប្រទេសប្រេស៊ីល ជម្លោះច្រើនតែកើតឡើងរវាងក្រុមហ៊ុនកាប់ឈើ អ្នកចិញ្ចឹមគោ និងអ្នកដទៃទៀតដែលរកចំណូលពីការកាប់ដើមឈើ, ជាមួយប្រជាជនរស់នៅក្នុងព្រៃដែលធ្វើកសិកម្ម រកជ័រឈើ និងធ្វើសិប្បកម្ម។ បន្ទាប់ពីព្រៃទឹកភ្លៀងនេះត្រូវបានបំផ្លាញមួយផ្នែកធំ កម្មករ និងពួកកុលសម្ព័ន្ធក៏បានបញ្ចុះបញ្ចូលរដ្ឋាភិបាលបានសម្រេចក្នុងការបង្កើត "ព្រៃឈើបម្រុងដែលអាចប្រើខ្លះ" (ព្រៃឈើមួយផ្នែកធំដែលការពារពីការកាប់បំផ្លាញ ប៉ុន្តែបើកឲ្យមានការប្រើប្រាស់ដោយដាក់កម្រិត)។

ជាអកុសល សូម្បីតែប្រជាជនដែលរស់នៅក្នុងព្រៃជាច្រើនឆ្នាំមកហើយ ក៏ត្រូវបានបដិសេធមិនឲ្យប្រើប្រាស់ "ព្រៃឈើបម្រុងដែលអាចប្រើខ្លះ" ដែរ។ ព្រៃឈើដែលពួកគេបានប្រយុទ្ធយ៉ាងស្វិតស្វាញដើម្បីការពារវា នឹងលែងការពារការចិញ្ចឹមជីវិតរបស់ពួកគេទៀតហើយ។



ប្រជាជននៅក្នុងព្រៃអភិរក្សរបស់សហគមន៍តាប៉ាចុស(Tapajos) ចិញ្ចឹមជីវិតតាមរបៀបបុរាណដោយការធ្វើកសិកម្ម បរបាញ់សត្វ និងប្រើប្រាស់ផលិតផលព្រៃឈើធ្វើជាកន្ត្រក ទូកថែវ និងសិប្បកម្មដទៃទៀត។ ប៉ុន្តែពួកគេក៏ត្រូវការឱសថ ប្រដាប់ប្រដា ឧស អគ្គិសនី និងអ្វីផ្សេងទៀតដែរ ដែលតម្រូវឲ្យពួកគេត្រូវរកប្រាក់ចំណូល។ ដោយមានជំនួយថវិកាខ្លះៗ ពួកគេបានបង្កើតរោងជាងសិប្បកម្មឈើមួយ ដោយឲ្យឈ្មោះថា រោងជាងខាបូខ្លូ(Caboclo) សម្រាប់ប្រជាជនខាបូខ្លូដែលរួមមានពពួកជនជាតិដើម ជនជាតិអាហ្វ្រិក និងពួកដើមកំណើតអឺរ៉ុប។ ពួកគេផលិតគ្រឿងសង្ហារិមដើម្បីលក់ក្នុងទីផ្សារក្នុងស្រុក និងក្នុងហាងនានាទូទាំងប្រទេសប្រេស៊ីល ដោយប្រើប្រាស់តែដើមឈើដែលកាប់រួចនៅលើដីឆ្ការធ្វើកសិកម្មប៉ុណ្ណោះ។

ប្រាក់ចំណូលទាំងនេះបាននាំឲ្យពួកគេពិចារណាអំពីការបង្កើនផលិតផលឈើបន្ថែមទៀតដើម្បីរកប្រាក់។ ប៉ុន្តែពួកគេមិនត្រូវបានអនុញ្ញាតឲ្យកាប់ដើមឈើដែលនៅដុះធម្មតាទេ លុះត្រាតែមាន "បញ្ជីសារពើភ័ណ្ឌព្រៃឈើ" និង "ផែនការគ្រប់គ្រងប្រកបដោយស្ថិរភាព" ដែលទទួលស្គាល់ដោយក្រសួងបរិស្ថាន។

ដើម្បីបំពេញឲ្យគ្រប់តាមតម្រូវការរបស់រដ្ឋាភិបាល ពួកគេត្រូវប្រមូលព័ត៌មានអំពីចំនួនឈើដែលមាននៅក្នុងព្រៃ និងចំនួនឈើថ្មីៗដែលដុះជារៀងរាល់ឆ្នាំ។ រដ្ឋាភិបាលមិនជឿថាអ្នកភូមិទាំងនោះអាចធ្វើរឿងនេះបានទេ ព្រោះពួកគេភាគច្រើនមិនចេះអក្សរ។ ប៉ុន្តែអ្នកភូមិគឺជាអ្នកជំនាញព្រៃឈើពិតប្រាកដ។ ពួកគេបាននាំផ្លូវអ្នកវិទ្យាសាស្ត្រផ្នែកបរិស្ថានឲ្យឆ្លងកាត់ព្រៃជាច្រើនឆ្នាំមកហើយ និងបង្រៀនអំពីរុក្ខជាតិនិងសត្វនៅក្នុងព្រៃទៀតផង។ ឥឡូវនេះអ្នកវិទ្យាសាស្ត្រទាំងនោះបានបង្រៀនពួកគាត់ឲ្យប្រើប្រាស់ឧបករណ៍សាមញ្ញមួយដើម្បីវាស់ស្ទង់ពីការលូតលាស់របស់ដើមឈើ និងគណនាថាដើមឈើដុះថ្មីមានចំនួនប៉ុន្មានក្នុងមួយឆ្នាំៗ។ ដោយការដាក់កម្រិតលើការប្រើប្រាស់ឈើមិនឲ្យខ្ពស់ជាងចំនួនដែលវាអាចដុះឡើងវិញក្នុងមួយឆ្នាំៗ អ្នកភូមិបានរៀបចំផែនការមួយដើម្បីបង្កើតផលិតផលដែលមានទំហំតូចៗប៉ុន្តែមានតម្លៃខ្ពស់ ដូចជាផ្ទុញនិងកៅអីសម្រាប់អ្នកលក់សាច់ជាដើម។

ក្រសួងបរិស្ថានក៏បានទទួលស្គាល់ផែនការរបស់ពួកគេ ហើយសព្វថ្ងៃរោងជាងខាបូខ្លូអនុញ្ញាតឲ្យពួកគេរកប្រាក់ចំណូលដោយមិនឲ្យប្រើប្រាស់ធនធានព្រៃឈើហួសកម្រិតឡើយ។

អ្នករស់នៅព្រៃនៃរោងជាងខាបូខ្លូ បានសម្រេចនូវកិច្ចការមួយដែលអ្នកវិទ្យាសាស្ត្រ អ្នកសេដ្ឋកិច្ច និងបុគ្គលិកអភិវឌ្ឍន៍ជាច្រើនបានព្យាយាមអស់ពេលជាយូរដើម្បីសម្រេចបាន នោះគឺការបង្កើតផែនការគ្រប់គ្រងព្រៃឈើដែលមានស្ថិរភាពសម្រាប់ទាំងសហគមន៍និងព្រៃឈើរបស់ពួកគេ។

# ការដាំដើមឈើឡើងវិញ

ភាពកម្រនៃព្រៃឈើបុរាណ(ព្រៃឈើចំណាស់ៗដែលមិនធ្លាប់ត្រូវបានកាប់ឆ្ការឬបំផ្លាញយ៉ាងធ្ងន់ធ្ងរ)កំពុងតែឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ នៅពេលដែលព្រៃឈើបុរាណអស់ពីដីទៅ វានឹងមិនលូតលាស់ឡើងវិញដើម្បីផ្តល់ជាជម្រកដល់រុក្ខជាតិនិងសត្វដូចកាលពីមុនទេ។ ប៉ុន្តែព្រៃឈើជំនាន់ទី២(ព្រៃឈើដែលត្រូវបានបំផ្លាញប៉ុន្តែកំពុងលូតលាស់ឡើងវិញ)អាចផ្តល់ធនធានយ៉ាងច្រើនដូចគ្នានឹងព្រៃឈើបុរាណដែរ បើមនុស្សទុកឲ្យវាលូតលាស់និងថែរក្សាជីវចម្រុះតាមសម្រួល។ ហើយព្រៃឈើដែលដាំឡើងវិញដោយមនុស្សនិងដែលបានគ្រប់គ្រងយ៉ាងល្អ ក៏អាចផ្តល់ធនធានយ៉ាងច្រើនដើម្បីគាំទ្រដល់សុខភាពសហគមន៍ដែរ។

ព្រៃឈើដែលមានសុខភាពល្អ ត្រូវការពេលយូរក្នុងការលូតលាស់ឡើងវិញ ប៉ុន្តែអ្នកធ្វើរឿងខ្លះដើម្បីជួយព្រៃឈើនេះបាន។ ការការពារសំណឹកដី ការរៀបចំដី និងការដាំដើមឈើក្នុងតំបន់ឬដើមឈើដែលសមស្របក្នុងតំបន់របស់អ្នក នឹងជួយធ្វើឲ្យព្រៃឈើលូតលាស់បានល្អ។ ការធ្វើតាមលំដាប់លំដោយធម្មជាតិនៃព្រៃឈើដែលដុះក្នុងព្រៃ គឺជាវិធីមួយទៀតក្នុងការជួយបង្កើតព្រៃឈើដែលមានសុភាពល្អ(មើលជំពូក11)។

## តើការដាំដើមឈើតែងតែមានប្រយោជន៍ឬ?

មុននឹងចាប់ផ្តើមគម្រោងដាំដើមឈើឡើងវិញនៅក្នុងសហគមន៍ ត្រូវប្រាកដថាវានឹងបំពេញតាមតម្រូវការរបស់សហគមន៍អ្នកនិងបរិស្ថានក្នុងតំបន់របស់អ្នក។ ជួនកាលដើមឈើខ្លះអាចប្រឆាំងនឹងដំណាំរបស់អ្នកព្រោះវាផ្តល់ទឹកនិងដីតិចតួច។ ជួនកាលវាគឺជាការងារច្រើនហួសពីសមត្ថភាពក្នុងការថែទាំដើមឈើតូចៗនៅក្នុងបរិស្ថានអាក្រក់។ ការដាំដើមឈើដែលយើងមិនអាចមើលថែបាន ឬដែលយើងនឹងមិនមើលថែ បណ្តាលឲ្យទទួលបរាជ័យនិងដើមឈើងាប់។

ប្រសិនបើសហគមន៍របស់អ្នកពឹងផ្អែកលើផលិតផលព្រៃឈើ, ដូចជាឈើឬផ្លែឈើ, ការដាំដើមឈើអាចជាវិធីដ៏ល្អមួយក្នុងការបង្កើតឡើងវិញនូវធនធានព្រៃឈើយ៉ាងឆាប់រហ័ស។ ប្រសិនបើសហគមន៍របស់អ្នកពឹងផ្អែកជាចម្បងទៅលើព្រៃឈើសម្រាប់ផ្តល់កន្លែងបរបាញ់សត្វ ឬសម្រាប់ការពារដី ខ្យល់ និងទឹក ដូច្នេះអ្នកអាចទទួលផលប្រយោជន៍បន្ថែមពីព្រៃដោយការការពារដីមួយផ្នែកនោះមិនឲ្យនរណាប្រើប្រាស់ក្នុងពេលដើមឈើកំពុងលូតលាស់ឡើងវិញដោយខ្លួនឯង។

ព្រៃឈើមិនមែនសុទ្ធតែត្រឹមត្រូវគ្រប់ទីកន្លែងនោះទេ។ ដើមឈើមួយចំនួនតូចដុះជាធម្មជាតិនៅលើវាលខ្សាច់ វាលភក់ ឬវាលស្មៅ។ ប្រសិនបើមនុស្សព្យាយាមដាំដើមឈើនៅលើតំបន់ទាំងនេះ វាអាចនឹងបង្អាក់តុល្យភាពរវាងដើមឈើនិងសត្វ។ ប៉ុន្តែនៅកន្លែងដទៃទៀតដែលមានដើមឈើតិចតួច, ដូចជានៅទីក្រុង, ការដាំដើមឈើតាមសងខាងផ្លូវថ្នល់ ក្បែររោងចក្រ និងក្នុងសួនច្បារ អាចកែលម្អសុខភាពនិងសុខុមាលភាពរបស់សហគមន៍បានយ៉ាងច្រើន។

### តើអ្នកណាជាម្ចាស់ដី ហើយច្បាប់ចែងដូចម្តេចខ្លះ?

ប្រសិនបើអ្នកចង់ដាំដើមឈើឡើងវិញនៅលើដីមួយ និងចង់ប្រើប្រាស់ផលិតផលវានៅពេលក្រោយ ត្រូវប្រាកដថាអ្នកនឹងត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ព្រៃឈើនេះនៅពេលវាបានដុះឡើងវិញហើយ។ ការស្គាល់ម្ចាស់កម្មសិទ្ធិស្របច្បាប់ និងការសុំការអនុញ្ញាតមុនពេលដាំដើមឈើ អាចជួយបង្ករបញ្ហាទាំងនេះនៅថ្ងៃក្រោយ។ ដីដែលធ្លាប់តែសោះកក្រោះគ្មានជីជាតិ នឹងក្លាយជាមានប្រយោជន៍ឡើងវិញនៅពេលវាត្រូវបានគ្របដណ្តប់ដោយព្រៃឈើដែលមានសុខភាពល្អ។ ម្យ៉ាងវិញទៀត នៅកន្លែងខ្លះមានច្បាប់ហាមឃាត់ប្រជាជនមិនឲ្យកាប់ឬប្រើប្រាស់ដើមឈើជាក់លាក់មួយចំនួន បើទោះជាពួកគេជាអ្នកដាំដើមឈើទាំងនេះក៏ដោយ។ ត្រូវស្វែងយល់ថាតើច្បាប់បែបនេះមាននៅក្នុងតំបន់របស់អ្នកឬទេ។

## ដើមឈើខុសៗគ្នាបំពេញតម្រូវការផ្សេងៗគ្នា

ប្រភេទដើមឈើដែលនឹងដាំឡើងវិញ ត្រូវសម្រេចចិត្តដោយផ្អែកលើតម្រូវការរបស់ប្រជាជនក្នុងសហគមន៍។










**ទោះបីវាត្រូវការពេលវេលានិងភាពអត់ធ្មត់បន្តិចក៏ដោយ តាមរយៈការប្រើប្រាស់ចំណេះដឹងរបស់មនុស្សគ្រប់គ្នានិងការពិចារណាពីតម្រូវការរបស់មនុស្សទាំងអស់ នោះអ្នកអាចបង្កើតផែនការដ៏ល្អមួយសម្រាប់សហគមន៍ទាំងមូលបាន។**